ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ..១៦៥៥........អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

## ស្តីពី

## ការកែសម្រួលម៉ោងបម្រើការងាររបស់អគ្គនាយកដ្ឋានពន្ធដារ

ឆ្លើយតបនឹងតម្រូវការនៃការប្រើប្រាស់សេវាសាធារណៈ និងក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងថែមមួយកម្រិតទៀតនូវប្រសិទ្ធភាពខ្ពស់ក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ក៏ដូចជារួមចំណែកជួយសម្រួលជូនអ្នកជាប់ពន្ធក្នុងការមកដាក់លិខិតប្រកាសបង់ពន្ធនៅចន្លោះម៉ោងសម្រាកពីការងារនៃថ្ងៃធ្វើការ ជាពិសេស ដើម្បីឲ្យមានភាពស៊ីសង្វាក់គ្នាជាមួយនឹងម៉ោងបម្រើការងាររបស់វិស័យធនាគារ និងសហគ្រាសឯកជនភាគច្រើន ក្នុងន័យសម្រួលដល់ដំណើរការចរន្តនៃការដាក់លិខិតប្រកាសបង់ប្រាក់ពន្ធនៅតាមស្ថាប័នដែលពាក់ព័ន្ធផងនោះ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនដំណឹងសាធារណជនទាំងអស់មេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើការកែសម្រួលម៉ោងបម្រើការងាររបស់មន្ត្រីរាជការពន្ធដារនៅតាមអង្គភាពមួយចំនួនក្រោមចំណុះ ដែលជាអង្គភាពប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអ្នកជាប់ពន្ធលើកិច្ចការប្រមូលចំណូលពន្ធ ដោយត្រូវ**<u>ចូលធ្វើការចាប់ពីម៉ោង ៨:០០ ព្រឹក រហូតដល់ ម៉ោង ១៦:៤៥ នាទីរសៀល ដោយមិនមានការឈប់សម្រាកពេលថ្ងៃត្រង់ទេ</u>។ ចំពោះមន្ត្រីដែលត្រូវប្រចាំការសម្រាប់បម្រើសេវាជូនអ្នកជាប់ពន្ធ នឹងត្រូវផ្លាស់វេនគ្នាសម្រាក<u>រយៈពេល៤៥នាទី</u> ដើម្បីទទួលទានអាហារថ្ងៃត្រង់នៅហ្នឹងកន្លែងធ្វើការ។**

ការកែសម្រួលម៉ោងបម្រើការងាររបស់មន្ត្រីរាជការពន្ធដារដូចបានជម្រាបជូនខាងលើ នឹងត្រូវផ្តើមអនុវត្តចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ នេះ តទៅ។

អាស្រ័យហេតុនេះ សូមលោកឧកញ៉ា លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងរួមសហការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីកសហវ
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ